# ការស្លាប់របស់ អៀង ធីរិទ្ធ

ឌី សុជាតា

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសជាសាធារណៈអំពីដំណឹងមរណៈភាពរបស់ អៀង ធីរិទ្ធ ដែលជាអតីតជនជាប់ចោទនៅក្នុងសំណុំរឿង ០០២។ អៀង ធីរិទ្ធ គឺជាសមាជិកជាន់ខ្ពស់ម្នាក់នៅក្នុងជួររដ្ឋាភិបាល និងបានកាន់មុខដំណែងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ កាលពីឆ្នាំ២០១០ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ អៀង ធីរិទ្ធ កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ។ អៀង ធីរិទ្ធ បានចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងទីក្រុងភ្នំពេញ ហើយបន្ទាប់មកទទួលបានសញ្ញាប័ត្រអក្សរសាស្ត្រអង់គ្លេសនៅប្រទេសបារាំង។ អៀង ធីរិទ្ធ បានរៀបការជាមួយ អៀង សារី នៅឆ្នាំ១៩៥១។ នៅឆ្នាំ១៩៥៧ អៀង ធីរិទ្ធ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ និងធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស។ ចំណែកបងស្រីរបស់ អៀង ធីរិទ្ធ ឈ្មោះ ខៀវ ប៉ុណ្ណារី បានរៀបការជាមួយ ប៉ុល ពត។ អៀងធីរិទ្ធត្រូវបានចោទពីបទជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួននិងសម្លាប់ សមាជិកមកពីក្រសួងសង្គមកិច្ច។ នៅឆ្នាំ១៩៩៦ អៀង ធីរិទ្ធ និង អៀង សារី បានចាកចេញពីខ្មែរក្រហម។

នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ បានបន្តតាំងពីពេលចាប់ខ្លួននៅឆ្នាំ២០០៧ រហូតដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១២ ទើបអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ ដោយមូលហេតុនៃការវិវឌ្ឍន៍នៃជំងឺវង្វេងវង្វាន់របស់ខ្លួនកាន់តែធ្ងន់ធ្ងរទៅៗ និងបានតែងតាំងអាណាព្យាបាលតាមផ្លូវច្បាប់ម្នាក់ ដែលត្រូវជាកូនស្រីបង្កើត។

គួររំឭកថា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌលើកទីមួយនៅខែវិច្ឆិកា ឆ្នាំ២០១១ បន្ទាប់ពីបានរកឃើញថា ជនជាប់ចោទពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ដោយបំបែកបទចោទប្រកាន់ចេញពីសំណុំរឿង០០២ និងផ្អាកនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល ដែលបង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទក្នុងរយៈពេល៦ខែទៀត ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងប្រឹងប្រែងក្នុងការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវវិធានការទាំងឡាយ ដែលមានក្នុងការជួយជនជាប់ចោទឲ្យមានភាពប្រសើរឡើង ដើម្បីអាចចូលរួមការ

ជំនុំជម្រះបាន ។ បន្ទាប់ ពីការបើកសវនាការបន្តបន្ទាប់ ដើម្បីពិភាក្សាលើសម្បទារបស់ជនជាប់ចោទ ដោយអង្គជំនុំជម្រះ និង ភាគីបានសួរដេញដោលអ្នកជំនាញផ្នែកវេជ្ជសាស្ត្រអស់ជាច្រើនលើកច្រើនសារ និងមានការប្តឹងឧទ្ធរណ៍ជំទាស់លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពីភាគីសហព្រះរាជអាជ្ញារួចមក អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចដោះលែងជនជាប់ចោទ ដោយដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ ភ្ជាប់នឹងលក្ខខណ្ឌមួយចំនួនរួមមាន ៖ ១) ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះ អំពីអាស័យដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅដោយពុំមានការអនុញ្ញាតពីអង្គ ជំនុំជម្រះឡើយ ២) ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ និង៣) ជនជាប់ចោទត្រូវគោរពតាមដីកាកោះ ដែលចេញដោយតុលាការ ។

ក្នុងចំណោមជនជាប់ចោទទាំងបួនរូបក្នុងសំណុំរឿង០០២ អៀង ធីរិទ្ធ គឺជាបុគ្គល តែម្នាក់ដែលទទួលបានការដោះលែងឲ្យនៅក្រៅឃុំ បន្ទាប់ពីមានការចោទប្រកាន់នៅចំពោះមុខសាលាក្តីខ្មែរក្រហម ។ ដំណឹងពីសម្បទាមិនគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដែលបណ្តាលឲ្យមានការដោះលែង អៀង ធីរិទ្ធ គឺជាស្ថានភាពមួយដែលពិបាកទទួលយកសម្រាប់ប្រជាជនខ្មែរ ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហមម្តងរួចទៅហើយ ។ មកដល់ពេលនេះ មានអតីតជនជាប់ចោទពីររូបនៅក្នុងសំណុំរឿង ០០២ បានទទួលមរណៈភាព គឺ អៀង សារី (ស្លាប់នៅឆ្នាំ២០១៣) និង អៀង ធីរិទ្ធ ដែលត្រូវជាប្រពន្ធរបស់ អៀង សារី ហើយក៏ជាបុគ្គលដ៏មានឥទ្ធិពល និងមានអំណាចនៅទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការស្លាប់របស់ អៀង ធីរិទ្ធ នៅពេលនេះបានធ្វើឲ្យការចោទប្រកាន់របស់តុលាការប្រឆាំងនឹង អៀង ធីរិទ្ធ ត្រូវបិទបញ្ចប់ទាំងស្រុង ។ ការបិទបញ្ចប់នេះក៏ពុំមានផលប៉ះពាល់ចំពោះជនជាប់ចោទទាំងពីររូបដែលនៅមានជីវិតនោះឡើយ ដោយមូលហេតុថា សំណុំរឿងរបស់ អៀង ធីរិទ្ធ ត្រូវបានបំបែកចេញតាំងពីឆ្នាំ២០១១មកម្ល៉េះ ។

អៀង ធីរិទ្ធ បានស្លាប់ស្របពេលដែលអង្គជំនុំជម្រះសាលាដំបូងកំពុងតែពិភាក្សាសួរដេញដោលលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងការសាងសង់ទំនប់ត្រពាំងថ្ម ដែលស្ថិតក្នុងភូមិភាគពាយ័ព្យ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង ធីរិទ្ធ ត្រូវបានបញ្ជូនឲ្យទៅស៊ើបអង្កេត និងរាយការណ៍ពីបញ្ហាសុខាភិបាលមួយចំនួនក្នុងភូមិភាគនេះ ហើយទំនងជាបានដឹងថា ប្រជាជនកម្ពុជាជាច្រើន នាក់កំពុងតែអត់ឃ្លានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ការពិត យុត្តិធម៌ ការផ្សះផ្សារ

ការទទួលខុសត្រូវ និង ប្រវត្តិសាស្ត្រ ត្រូវបាត់បង់បន្ទាប់ពីមរណៈភាពនេះ បើទោះបីជាមានការដាក់ឲ្យ
នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរហូតដល់ពេលស្លាប់ក៏ដោយ ។